# The Commonwealth of Massachusetts

*Committee for Public Counsel Services*
*Immigration Impact Unit*
*21 McGrath Highway, Somerville, MA 02143*

**ANTHONY J. BENEDETTI**
CHIEF COUNSEL

**WENDY S. WAYNE**
DIRECTOR

## <u>សិទ្ធិរបស់លោក-អ្នកពេលសម្ភាសន៍ជាមួយមន្រ្តីអន្តោប្រវេសន៍ខណៈនៅក្នុងគុក ឬពន្ធនាគារក្នុងរដ្ឋម៉ាស្សាជូសេត្ស៍</u>

ភ្នាក់ងារសមត្ថកិច្ចគយ និងអន្តោប្រវេសន៍ ("ICE") ធ្វើការក្នុងពន្ធនាគារ, មន្ទីរឃុំឃាំងអប់រំ, និងគុកក្នុងរដ្ឋម៉ាស្សាជូសេត្ស៍ អាចព្យាយាម សម្ភាសន៍ ឬសុំឱ្យលោក-អ្នកចុះហត្ថលេខាឯកសារផ្សេងៗ។ មន្ត្រីមន្ទីរឃុំឃាំងដ៏ទៀតដែលធ្វើការជាមួយ ICE អាចព្យាយាមសាកសួរលោក-អ្នក ផងដែរ ពីប្រវត្តិអន្តោប្រវេសន៍ ឬបទឧក្រិដ្ឋរបស់លោក-អ្នក។ អ្វីដែលលោក-អ្នកនិយាយទៅកាន់មន្ត្រី ICE ឬមន្ត្រីមន្ទីរឃុំឃាំងណាម្នាក់ ដែលធ្វើការជាមួយ ICE អាចបង្ករឱ្យ ICE ចាប់ផ្តើមដំណើរការនីតិវិធីបញ្ជូនទៅស្រុកវិញប្រឆាំងនឹងលោក-អ្នក។ ប្រសិនបើមន្ត្រីណាម្នាក់ ព្យាយាមសួរ លោក-អ្នក ឬសុំឱ្យលោក-អ្នកចុះហត្ថលេខាលើអ្វីមួយ វាជាការសំខាន់ណាស់ដែលលោក-អ្នកត្រូវដឹងពីសិទ្ធិរបស់លោក-អ្នក:

(1) **ការសម្ភាសន៍នានារឿងអន្តោប្រវេសន៍គឺជាការឆ្លើយដោយស្ម័គ្រចិត្ត។** លោក-អ្នកមិនចាំបាច់និយាយជាមួយមន្ត្រីណាម្នាក់ពីប្រវត្តិ អន្តោប្រវេសន៍ ឬបទឧក្រិដ្ឋរបស់លោក-អ្នកឡើយ។
(2) **លោក-អ្នកមានសិទ្ធិនៅស្ងៀម។** អ្វីដែលលោក-អ្នកនិយាយជាមួយមន្ត្រី ICE ឬមន្ត្រីមន្ទីរឃុំឃាំងណាម្នាក់ដែលធ្វើការឱ្យ ICE (រួមទាំងព័ត៌មានសាមញ្ញៗ ដូចជា តើលោក-អ្នកកើតនៅឯណា) អាច ហើយនឹងត្រូវគេប្រឆាំងនឹងលោក-អ្នកនៅតុលាការអន្តោ ប្រវេសន៍ ឬតុលាការផ្នែកបទឧក្រិដ្ឋ។
(3) **លោក-អ្នកមិនចាំបាច់ចុះហត្ថលេខាលើឯកសារណាដែល ICE ឬមន្ត្រីណាម្នាក់ដែលយកមកឱ្យលោក-អ្នកឡើយ។** អ្វីដែលមន្ត្រី ICE ឬមន្ត្រីមន្ទីរឃុំឃាំងណាម្នាក់ដែលធ្វើការឱ្យ ICE សុំឱ្យលោក-អ្នកចុះហត្ថលេខាអាច ហើយនឹងត្រូវគេប្រើប្រាស់ប្រឆាំងនឹង លោក-អ្នកនៅតុលាការអន្តោប្រវេសន៍ ឬតុលាការផ្នែកបទឧក្រិដ្ឋ។
(4) **ចូរទាក់ទងមេធាវីរបស់លោក-អ្នក**_____________________________ (attorney name) នៅ ___________________________(attorney number) ដើម្បីរាយការណ៍នូវការសុំឱ្យមានសម្ភាសន៍, ការសួរនាំ, ការធ្វើបាប, ឬបញ្ហាផ្សេងៗ ទៀតដែលលោក-អ្នកជួបប្រទះ។

*តើខ្ញុំគួរតែធ្វើយ៉ាងណា បើសិនជាមន្ត្រី ICE ឬមន្ត្រីនៅមន្ទីរ ឃុំឃាំងដែលធ្វើការជាមួយ ICE មកនិយាយជាមួយខ្ញុំ?*
បើសិនជាភ្នាក់ងារ ICE ឬមន្ត្រីណាម្នាក់មកនិយាយជាមួយលោក-អ្នក ហើយអ្នកមិនចង់និយាយជាមួយគេដោយមិនបានពិភាក្សាជាមួយ មេធាវី ឬក៏ដោយមិនមានវត្តមានរបស់មេធាវី លោក-អ្នកជំរាបមន្ត្រីនោះថា លោក-អ្នកមិនចង់និយាយអ្វីទេ ហើយមិនអាចនិយាយជាមួយគាត់ បានដោយពុំមានមេធាវីរបស់លោក-អ្នកមានវត្តមាន។ ចូរប្រគល់កំណាត់ខាងក្រោមនៃក្រដាសនេះដល់មន្ត្រីនោះ។ ក្រដាសនេះជំរាបទៅមន្ត្រី ICE នោះឱ្យទាក់ទងមេធាវីរបស់លោក-អ្នក ហើយលោក-អ្នកនឹងមិនឆ្លើយសំណួរអ្វីដោយមិនមានវត្តមានមេធាវីរបស់លោក-អ្នកឡើយ។ កុំនិយាយអ្វីវែងឆ្ងាយដាក់មន្ត្រីនោះ។ ជូនដំណឹងទៅមេធាវីរបស់លោក-អ្នកឱ្យបានលឿនបំផុតតាមដែលអាចធ្វើបានទាក់ទងសំណួរនេះ។

*ហែកត្រង់នេះ (Tear here)* ------------------------------------------------------------------------------------------------

**To ICE Officer or Correctional Officer:**

I, ______________________________________, hereby invoke my right to remain silent for the purpose of any interview with immigration officials without my lawyer present. If you wish to speak with me, please contact my lawyer: ____________________________________________________________

(attorney name, phone number, email address)

Khmer - January 2017